# មូលដ្ឋានគ្រឹះ

## ប្រវត្តិវិទ្យា

# អត្ថន័យពាក្យប្រវត្តិសាស្ត្រ

**ប្រវត្តិសាស្ត្រ** គឺជាកម្រងហេតុការណ៍ និងព្រឹត្តិការណ៍អតីតកាលរបស់មនុស្ស ចំណេះដឹងអតីតកាលនៃមនុស្សជាតិនិងសង្គមមនុស្ស។

**ប្រវត្តិវិទ្យា** គឺជាការសិក្សាអំពីហេតុការណ៍ ព្រឹត្តិការណ៍ បទពិសោធន៍អតីតកាលរបស់មនុស្សជាតិ ដោយពឹងផ្អែកលើកំណត់ត្រា និងសក្ខីកម្ម សម្រាប់សហសម័យ។

**បុរេប្រវត្តិសាស្ត្រ** គឺជាការសិក្សាអំពីអតីតកាលដ៏យូរលង់ណាស់មកហើយ តាំងពីមិនទាន់មានអក្សរដោយផ្អែកលើរបាយការផ្អែកបុរាណវិទ្យា។

**ប្រូតូប្រវត្តិសាស្ត្រ** គឺការសិក្សាអតីតកាលផ្អែកលើប្រភពឯកសារក្រៅស្រុកដែលសរសេរ ឬការកត់ត្រាអំពីស្រុកមួយដោយអ្នកដំណើរបរទេស។

**ប្រវត្តិសាស្ត្រសហសម័យ** ជាការសិក្សារឿងរ៉ាវព្រឹត្តិការណ៍ដែលទើបកើតកន្លងផុតថ្មីៗ ដោយព្រឹត្តិការណ៍នោះឯងនៅមានឥទ្ធិពល ឬប៉ះពាល់ដល់សង្គមបច្ចុប្បន្ននៅឡើយ...។

# ឯកសារប្រវត្តិវិទ្យា

**ឯកសារគ** — មាន រូប គំនូ របស់របរប្រើប្រាស់...



**ឯកសារសរសេរ** — មានសិលាចារឹក សាស្ត្រាស្លឹករឹត...



**ឯកសាររឿងនិទាន** — រឿងប្រជាប្រិយតៗគ្នា ឬរឿងប្រវត្តិសាស្ត្រ...



# តើរៀនប្រវត្តិវិទ្យា មានសារៈសំខាន់អ្វីខ្លះ?





អ្នកនិពន្ធខ្សែភាពយន្តរឿង A Little Nonya បាននិយាយថា

“មនុស្សដែលមិនស្គាល់ប្រវត្តិរបស់ដូនតាខ្លួន ប្រៀបដូចជាស្លឹកឈើមួយ

សន្លឹក ដែលមិនដឹងថាខ្លួនកំពុងនៅលើដើមណាមួយ”

“ចំណេះដឹងប្រវត្តិសាស្ត្រ មិនត្រឹមតែធ្វើឱ្យយើងឆ្លាតនៅពេលអនាគត

នោះទេ

តែវាធ្វើឱ្យយើងឆ្លាតគ្រប់ពេលវេលា”

Burckhardt

# គុណតម្លៃប្រវត្តិវិទ្យា

## តម្លៃជាអប់រំ

ផ្តល់ចំណេះដឹងដល់
អ្នកសិក្សាឲ្យយកគំរូ
ល្អ មានឧត្តមគតិ
ស្នេហាជាតិ និងឆន្ទៈ
ការពារជាតិមាតុភូមិ...

## តម្លៃជាវប្បធម៌

ស្គាល់ពីអត្តសញ្ញាណ
អរិយធម៌ជាតិ អន្តរ
ជាតិ បណ្តុះស្មារតី
ស្នេហាបេតិកភណ្ឌ
ជាតិ អន្តរជាតិ...

## តម្លៃជាសីលធម៌

បណ្តុះស្មារតីសាមគ្គី
ជាតិ អន្តរជាតិ មាន
ទំនាក់ទំនងល្អជាស
កល មិនរើសអើងពូជ
សាសន៍...

## តម្លៃជាការងារ

បង្កើតមនុស្សអាជីវកម្ម
ពូកែ អ្នកវិជ្ជាជីវៈ អ្នក
នយោបាយ គ្រូបង្រៀន
អ្នកស្រាវជ្រាវ...

## តម្លៃជាការរស់នៅ

ចេះបត់បែនតាមកា
លៈទេសៈ ឆាប់ស្គាល់
ពីស្ថានភាពសង្គម
សម្របខ្លួនសង្គមទាន់
ពេលវេលា...

# កាលវិទ្យា

- និយមន័យៈ កាលវិទ្យាជាវិទ្យាស្យង់នៃកាលបរិច្ឆេទ( ថ្ងៃ ខែ ឆ្នាំ ) សម្រាប់ចុះកាលកំណត់នៃហេតុការណ៍អាក្រក់ឬល្អណាមួយ ដើម្បីឱ្យអ្នកសិក្សាពីរយៈពេលនៃព្រឹត្តិការណ៍ទាំងនោះ។
- ឧទាហរណ៍ៈ ប្រទេសកម្ពុជាទទួលបានឯករាជ្យពេញលេញពីបារាំងនៅថ្ងៃទី ៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣។

គេចែកកាលវិទ្យា ជា**សករាជ** និង **រង្វាស់ពេល**

# អំពីសករាជ

✍សករាជ៖ ជាការរាប់ថ្ងៃ ខែ ឆ្នាំ តាមកាលកំណត់ដែលតាំងទុកពីមួយរៀងមក ដោយមានបុគ្គលអស្ចារ្យណាមួយដែលពួកជនានុជនគោរព ត្រូវបានកត់ត្រាមិនឲ្យបាត់ រាប់តាំងពីដើមរៀងមក។






# រង្វាស់ពេល

| | | |
|---|---|---|
| ១ទសវត្ស | = | ១០ឆ្នាំ |
| ១សតវត្ស | = | ១០០ឆ្នាំ |
| ១សហស្សវត្ស | = | ១០០០ឆ្នាំ |

## រូបមន្តគណនាវត្សរ៍ទាំង៣

- ទសវត្ស=គ.ស.(លុបចុង១ខ្ទង់)+១
- សតវត្ស=គ.ស.(លុបចុង២ខ្ទង់)+១
- សហស្សវត្ស=គ.ស.(លុបចុង៣ខ្ទង់)+១

ឧ.គ.ស.២០២១

⇨ទសវត្ស=២០២~~១~~=២០២+១=២០៣

⇨សតវត្ស=២០~~២១~~=២០+១=២១

⇨សហស្សវត្ស=២~~០២១~~=២+១=៣

# រង្វាស់ពេល

ប្រតិទិនចន្ទគតិ

↓

១២ខែ

↓

៣០ឬ២៨ថ្ងៃ/១ខែ

ប្រតិទិនសុរិយគតិ

↓

១២ខែ

↓

៣០ឬ៣១ថ្ងៃ/១ខែ

↓

២៨ឬ២៩ថ្ងៃ/ខែកុម្ភៈ



## ឆ្នាំខ្មែរ ទាំង១២

Die Khmer Jahre im Zwölfjahrzuklus




## ខែសុរិយគតិ ទាំង១២

12 Monate im Sonnenzyklus




## ខែចន្ទគតិ ទាំង១២

12 Monate im Mondzyklus



# គំនិតអំពីសកល




គំនិតតាំងពីបុរាណដល់ស.វទី១៦




គំនិតចាប់ពីស.វទី១៧មក

# ប្រវត្តិ ប្រតិទិនសកល

MEY Sophy

| | |
|---|---|
| Quinti | 5 |
| Sexti | 6 |
| Septo | 7 |
| Octo | 8 |
| Novo | 9 |
| Deci | 10 |

## ហេតុអ្វី ខែកុម្ភៈ មានចំនួនថ្ងៃតិចជាងគេ?

ដើមឡើយ .... នៅទ្វីបអឺរ៉ុបគេនិយមប្រើ ប្រតិទិនរ៉ូម៉ាំង :

1 - រាប់រ៉ូមសកករាជ ជាគោល
2 - រាប់ខែមិនា ជាខែទី១
3 - រាប់ខែកុម្ភៈ ជាខែទី១២ ( ទើបបានជាខែកុម្ភៈ មានចំនួនថ្ងៃតិចជាងគេ ) !
4 - ពីសវ.ទី៧ ដល់ ៨ឆ្នាំមុនគស. ប្រតិទិនរ៉ូម៉ាំង បានប្តូរមកជាប្រតិទិនព្រះចៅ Julius Caesar
5 - នៅគស.1582 - 1583 ប៉ាប Gregoire ទី10 បានកែតម្រូវម្តងទៀត រាប់ខែមករា ជាខែទី១ ខែទី10 ជាខែទី១២ ....
6 - សវ.ទី ១៦ ប្រតិទិនហ្គ្រេហ្គរ បានដាក់ប្រើជាទូរទៅក្នុងសកលលោក ពីសវ.ទី ១៦ រហូតសព្វថ្ងៃ ! .....

| ប្រតិទិនរ៉ូម៉ាំង (ភាសាឡាតាំង) | | ប្រតិទិនព្រះចៅហ្ស៊ូល (ភាសាឡាតាំង) | | ប្រតិទិនហ្គ្រេហ្គរ (ភាសាអង់គ្លេស) | |
|---|---|---|---|---|---|
| 1 - Martius | នាមអាទិទេព | 1 - Martius | នាមអាទិទេព | 1 - January | នាមអាទិទេព |
| 2 - Aprilis | នាមអាទិទេព | 2 - Aprilis | នាមអាទិទេព | 2 - February | នាមអាទិទេព |
| 3 - Maïus | នាមអាទិទេព | 3 - Maïus | នាមអាទិទេព | 3 - March | នាមអាទិទេព |
| 4 - Junius | នាមអាទិទេព | 4 - Junius | នាមអាទិទេព | 4 - April | នាមអាទិទេព |
| 5 - Quintilis | ទីប្រាំ | 5 - Julius | នាមព្រះចៅ Julius Caesar | 5 - May | នាមអាទិទេព |
| 6 - Sextilis | ទីប្រាំមួយ | 6 - Augustus | នាមព្រះចៅ Augustus Caesar | 6 - June | នាមអាទិទេព |
| 7 - September | ទីប្រាំពីរ | 7 - September | ទីប្រាំពីរ | 7 - July | នាមព្រះចៅ Julius Caesar |
| 8 - October | ទីប្រាំបី | 8 - October | ទីប្រាំបី | 8 - August | នាមព្រះចៅ Augustus Caesar |
| 9 - November | ទីប្រាំបួន | 9 - November | ទីប្រាំបួន | 9 - September | ទីប្រាំពីរ |
| 10 - December | ទីដប់ | 10 - December | ទីដប់ | 10 - October | ទីប្រាំបី |
| 11 - Januarius | នាមអាទិទេព | 11 - Januarius | នាមអាទិទេព | 11 - November | ទីប្រាំបួន |
| 12 - Februarius | នាមអាទិទេព | 12 - Februarius | នាមអាទិទេព | 12 - December | ទីដប់ |

៣ ៗ ១០
៧

ថ្ងៃ អង្គារ ៧រោច ខែ ភទ្របទ

១
២ ៗ ៩

ថ្ងៃ ចន្ទ ១កើត ខែ ស្រាពណ៍

# ការវិវត្តន៍សម័យកាល ប្រវត្តិសាស្ត្រប្រទេសកម្ពុជា

## បុរេប្រវត្តិសាស្ត្រ

- យុគថ្មបំបែក — ៦០០ ០០០-១២ ០០០BC
- យុគថ្មរំលីង — ៨០០០-២០០០BC
- យុគលោហៈ — ២០០០-១០០BC

## សម័យបុរាណ-កណ្តាល

- សម័យអាណាចក្រភ្នំ — ៥២-៥៥០
- សម័យអាណាចក្រចេនឡា — ៥៥០-៨០០
- សម័យអង្គរ — ៨០២-១៤៣២
- សម័យចតុមុខ — ១៤៣២-១៥២៧
- សម័យលង្វែក — ១៥២៧-១៦២០
- សម័យឧដុង្គ — ១៦២០-១៨៦៣

## សម័យទំនើប

- អាណានិគមនិយមបារាំង — ១៨៦៣-១៩៥៣
- សម័យសង្គមរាស្ត្រនិយម — ១៩៥៥-១៩៧០
- សម័យសាធារណរដ្ឋខ្មែរ — ១៩៧០-១៩៧៥
- សម័យកម្ពុជាប្រជាធិបតេយ្យ — ១៩៧៥-១៩៧៩
- សាធារណរដ្ឋប្រជាមានិតកម្ពុជា — ១៩៧៩-១៩៨៩
- សម័យរដ្ឋកម្ពុជា — ១៩៨៩-១៩៩១
- សម័យអ៊ុនតាក់ — ១៩៩១-១៩៩៣
- ព្រះរាជាណាចក្រកម្ពុជាទី២ — ១៩៩៣-បច្ចុប្បន្ន

ចែករំលែកប្រវត្តិវិទ្យា

ថ្នាក់ទី

១០ ៩ ៨ ១១ ១២ ៧

Share History